**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**

# សេចក្តីប្រកាសព័ត៌មាន
## ស្តីពីលទ្ធផលនៃកិច្ចប្រជុំលើកទី២ របស់គណៈកម្មាធិការអចិន្ត្រៃយ៍ មជ្ឈមណ្ឌលតំបន់អាស៊ានសម្រាប់សកម្មភាពមីន (ARMAC)

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានរៀបចំកិច្ចប្រជុំលើកទី២ របស់គណៈកម្មាធិការអចិន្ត្រៃយ៍នៃមជ្ឈមណ្ឌលតំបន់អាស៊ានសម្រាប់សកម្មភាពមីន (ARMAC) នៅថ្ងៃទី ២១ ខែវិច្ឆិកា ឆ្នាំ២០១៦ នៅទីស្នាក់ការ ARMAC ក្នុងរាជធានីភ្នំពេញ ប្រទេសកម្ពុជា។ កិច្ចប្រជុំនេះដឹកនាំដោយ ឯកឧត្តម ប្រាស៊ីត សាយ៉ាស៊ីត (Prasith Sayasith) ឯកអគ្គរាជទូតវិសាមញ្ញ និងពេញ សមត្ថភាព របស់សាធារណរដ្ឋប្រជាធិប្បតេយ្យប្រជាមានិតឡាវ ប្រចាំព្រះរាជាណាចក្រកម្ពុជា ដែលជាប្រធាននៃគណៈកម្មាធិការអចិន្ត្រៃយ៍របស់ ARMAC និងមានការចូលរួមពីតំណាងរបស់ប្រទេសសមាជិកអាស៊ានទាំងអស់ និងលេខាធិការដ្ឋានអាស៊ាន។

កិច្ចប្រជុំបានធ្វើការពិភាក្សាអំពីការដាក់ឱ្យដំណើរការមជ្ឈមណ្ឌល ARMAC និងបានឯកភាពតាមសំណើរបស់កម្ពុជាឱ្យមាននាយកប្រតិបត្តិបណ្តោះអាសន្ន (Interim Executive Director) របស់មជ្ឈមណ្ឌល ARMAC ដើម្បីគ្រប់គ្រងការងារប្រចាំថ្ងៃរបស់មជ្ឈមណ្ឌលនេះ និងជួយគាំទ្រដល់ការងាររបស់ គណៈកម្មាធិការអចិន្ត្រៃយ៍ រហូតដល់ពេលដែលនាយកប្រតិបត្តិត្រូវបានជ្រើសរើសជាស្ថាពរ។ កិច្ចប្រជុំក៏បានអនុម័តគោលការណ៍ណែនាំស្តីពីការជ្រើសរើសនាយកប្រតិបត្តិដែលនឹងត្រូវប្រើប្រាស់ជាឯកសារយោងសម្រាប់ ដំណើរការជ្រើសរើសនាយកប្រតិបត្តិនៃមជ្ឈមណ្ឌល ARMAC នាពេលខាងមុខនេះ។ កិច្ចប្រជុំក៏បានពិភាក្សា និងកែសម្រួលសេចក្តីព្រាងថវិកាប្រចាំឆ្នាំសម្រាប់ដំណើរការ ARMAC និងផែនការការងារពីរឆ្នាំ (២០១៧-២០១៨) របស់មជ្ឈមណ្ឌលផងដែរ។

នៅពេលចាប់ផ្តើមប្រតិបត្តិការពេញលេញ មជ្ឈមណ្ឌល ARMAC នឹងដើរតួនាទីជាមជ្ឈមណ្ឌលឧត្តមភាពសម្រាប់ជួយប្រទេសសមាជិកអាស៊ាន ដែលមានចំណាប់អារម្មណ៍ ក្នុងការស្រាវជ្រាវ ចែករំលែកចំណេះដឹង និងលើកកម្ពស់ការយល់ដឹងស្តីពីផលប៉ះពាល់នៃសំណល់ជាតិផ្ទុះពីសង្គ្រាម និងលើកទឹកចិត្តឲ្យមានកិច្ចខិតខំប្រឹងប្រែង ដើម្បីដោះស្រាយបញ្ហានេះ។

ភ្នំពេញ ថ្ងៃទី ២៣ ខែវិច្ឆិកា ឆ្នាំ ២០១៦

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ទូរស័ព្ទ : (855) 23 214 441, 216 122
ទូរសារ : (855) 23 216 144, 216 141
អ៊ីម៉ែល : mfaic@mfa.gov.kh